United Nations
Educational, Scientific and
Cultural Organization

Organisation
des Nations Unies
pour l'éducation,
la science et la culture

# សេចក្តីប្រកាសព័ត៌មាន

## ពិធីសម្ពោធពិព័រណ៌មិនអចិន្ត្រៃយ៍ស្តីអំពី

## «មរតកយើងទាំងអស់គ្នា៖ ស្វែង យល់អំពីរមណីយដ្ឋាន បេតិកភណ្ឌលោកនៅ ប្រទេស កម្ពុជា ឡាវ និង វៀតណាម»

**នៅសារមន្ទីរជាតិអង្គរ នាថ្ងៃទី ២៦ ខែមេសា ឆ្នាំ២០១៣ វេលាម៉ោង ៥:៣០ ល្ងាច**

ពិធីសម្ពោធពិព័រណ៌មិនអចិន្ត្រៃយ៍ស្តីអំពី «មរតកយើងទាំងអស់គ្នា៖ ស្វែងយល់អំពីរមណីយដ្ឋានបេតិកភណ្ឌពិភពលោកនៅប្រទេស កម្ពុជា ឡាវ និងវៀតណាម» ដែលនឹងប្រព្រឹត្តិទៅនៅថ្ងៃទី២៦ ខែមេសា ឆ្នាំ ២០១៣ នៅសារមន្ទីរជាតិអង្គរនេះគឺជាសមិទ្ធផលនៃគម្រោងស្តីអំពី «ការធ្វើឲ្យរស់រានជីវិតឡើងវិញនូវសារមន្ទីរតាមរមណីយដ្ឋានបេតិកភណ្ឌពិភពលោកនៅប្រទេស កម្ពុជា ឡាវ និងវៀតណាម» ដែលឧបត្ថម្ភថវិកាដោយមូលនិធិជប៉ុនតាមរយៈអង្គការយូណេស្កូ។ គម្រោងនេះចាប់ផ្តើមឡើងតាំងពីខែកក្កដា ឆ្នាំ២០១១ និងមានសិក្ខាសាលាចំនួនពីរលើកត្រូវបានធ្វើឡើងក្នុងក្របខ័ណ្ឌគម្រោងនេះផងដែរ។ សិក្ខាសាលាទីមួយបានរៀបចំឡើងនៅទីក្រុងហាណូនៃប្រទេសវៀតណាមក្នុងឆ្នាំ២០១១និង សិក្ខាសាលាទីពីរបានធ្វើនៅខេត្តសៀមរាបនៃប្រទេសកម្ពុជាក្នុងឆ្នាំ២០១២។ សិក្ខាសាលាទាំងពីរលើកនោះមានសមាជិកមកពីសារមន្ទីរចំនួនប្រាំបួនចូលរួម។ សារមន្ទីរបួននៃប្រទេសកម្ពុជាគឺ សារមន្ទីរជាតិកម្ពុជា សារមន្ទីរព្រះនរោត្តមសីហនុអង្គរ សារមន្ទីរជាតិអង្គរ និងសារមន្ទីរធម្មជាតិសកលសម្តេចតេជោហ៊ុនសែន។ សារមន្ទីរបួនផ្សេងទៀតនៃប្រទេសវៀតណាមគឺ មណ្ឌលអភិរក្សបេតិកភណ្ឌពិភពលោកថាងឡុង, សារមន្ទីរដាណាងអំពីចម្លាក់ចាម, គណៈគ្រប់គ្រងបេតិកភណ្ឌពិភពលោកមុីសឺន និង មណ្ឌលអភិរក្សបន្ទាយហ្វ និងសារមន្ទីរវត្តភូនៃប្រទេសឡាវ។

ពិព័រណ៌ស្តីអំពី «មរតកយើងទាំងអស់គ្នា៖ ស្វែងយល់អំពីរមណីយដ្ឋានបេតិកភណ្ឌពិភពលោកនៅប្រទេសកម្ពុជា ឡាវ និងវៀតណាម»នេះ នឹងដាក់តាំងនៅតាមសារមន្ទីរទាំងប្រាំបួនដែលបានរៀបរាប់ខាងលើ។ ចំពោះប្រទេសកម្ពុជា នេះគឺជាលើកទីបីនៃការសម្ពោធពិព័រណ៌បែបនេះ។ ការសម្ពោធដំបូងបានប្រព្រឹត្តិទៅនៅសារមន្ទីរព្រះនរោត្តមសីហនុអង្គរនៅខេត្តសៀមរាបកាលពីខែធ្នូ ឆ្នាំ២០១២។ ការសម្ពោធទីពីរគឺនៅសារមន្ទីរជាតិកម្ពុជា នាខែកុម្ភៈ ឆ្នាំ២០១៣។ ការសម្ពោធចុងក្រោយនឹងប្រព្រឹត្តិទៅនៅសារមន្ទីរធម្មជាតិសកលសម្តេចតេជោហ៊ុនសែនក្នុងឆ្នាំ២០១៣នេះផងដែរ។

ពិព័រណ៌នេះមានផ្ទាំងព័ត៌មានចំនួនបួនប្រភេទ។ ប្រភេទទីមួយមានប្រធានបទរៀបរាប់អំពីគោលគំនិតនៃអនុសញ្ញាបេតិកភណ្ឌពិភពលោក, ប្រវត្តិទីតាំង និងតម្លៃជាសកលនៃរមណីយដ្ឋានបេតិកភណ្ឌទាំងអស់នោះ។ ប្រភេទទីពីរមានប្រធានបទបង្ហាញអំពីធម្មជាតិនិងទេវកថា។ ប្រភេទទីបីបង្ហាញអំពីពាណិជ្ជកម្មនិងការផ្លាស់ប្តូរ។ រីឯប្រភេទទីបួនគឺជាក្រុមពិសេសមានប្រធានផ្សេងៗអាស្រ័យតាមសារមន្ទីរនីមួយៗ។ ដោយឡែកសម្រាប់សារមន្ទីរជាតិអង្គរនឹងបង្ហាញអំពី «ព្រះបាទជ័យវរ្ម័នទី៧៖ ជីវិត និង ការប្រតិបត្តិសាសនា»។

បន្ថែមពីលើពិព័រណ៌នេះទៅទៀត សារមន្ទីរជាតិអង្គរ ក៏ដូចជាសារមន្ទីរទាំងប្រាំបីផ្សេងទៀតនឹងរៀបចំកម្មវិធីអប់រំដល់សិស្សានុសិស្សរហូតដល់ដំណាច់ខែមិថុនា ឆ្នាំ២០១៣។

គោលបំណងសំខាន់នៃពិព័រណ៌នេះ គឺដើម្បីបង្ហាញពីទំនាក់ទំនងគ្នាជាប្រវត្តិសាស្ត្ររវាងរមណីយដ្ឋានបេតិកភណ្ឌពិភពលោក រួមទាំងប្រជាជនទាំងឡាយដែលរស់នៅក្នុងតំបន់ឥណ្ឌូចិននេះផងដែរ៕